Reading Book

ពិភពរឿងនិទាន

The World of Stories

រឿង ភ្នំសន្ទុក

Phnom Santouk



សៀវភៅជាប្រភពនៃចំណេះដឹង

Books are the source of knowledge


កាលពីព្រេងនាយ មានស្តេចមួយអង្គ ទ្រង់មានព្រះអគ្គមហេសី និង
ព្រះរាជបុត្រមួយអង្គព្រមទាំងស្រីស្នំក្រមការ សេនាទាហាន និងនាម៉ឺន
សព្វមុខមន្ត្រីជាច្រើន។

Once upon a time, there was a King, his wife and a son as well as a lot of women servants, knights and other highranking officers.




ស្តេចមានព្រះរាជបញ្ជាឱ្យប្រជារាស្ត្រកាប់ឆ្ការព្រៃមួយកន្លែងសង់ប្រាសាទ
ព្រះរាជវាំង និង គុហា។ ត្រង់ទីនោះក៏ជាប់ឈ្មោះថា **ភូមិប្រាសាទ**។

The King ordered the people to cut down the forest in order to build the royal palace and a temple there. It was named "Brasat village".



លុះសង់ប្រាសាទរួចហើយ ព្រះរាជាត្រាស់បង្គាប់ឱ្យកាប់ឆ្ការព្រៃមួយ
កន្លែងទៀត នៅខាងជើងឈាងខាងលិចនៃប្រាសាទនោះ ជាកន្លែង
សម្រាប់ស្រីស្នំ មានកំពែងជុំវិញដែលសព្វថ្ងៃជាប់ឈ្មោះថា **ភូមិវាំង**។

After Brasat was already built, the King ordered the people to cut down another forest at the northwest of Brasat to build another place with stone wall for women sevants.That place was called royal palace village or “Phum Vaing” ever since.



លុះធ្វើព្រះរាជវាំងរួចរាល់ហើយ ទ្រង់ត្រាស់បង្គាប់ឱ្យកាប់ឆ្ការព្រៃមួយកន្លែងទៀត នៅខាងលិចប្រាសាទដើម្បីសង់ឃ្លាំងសម្រាប់ដាក់ព្រះរាជទ្រព្យ ទើបនៅកន្លែងនោះជាប់ឈ្មោះថា **ភូមិសង់ឃ្លាំង**។


After the royal palace was already constructed; the King ordered the people to cut down another forest at the west of Brasat to build a warehouse to store his assets. It was called "Phum Sangklaing"



កាលនោះ ព្រះរាជាបង្គាប់ឱ្យឆ្កាព្រៃមួយកន្លែងទៀត នៅខាងលិចឈាង ខាងត្បូងភូមិតាំងក្រសាំង សម្រាប់លំនៅរបស់អ្នកចាំបក់ថ្វាយស្តេច ទីនោះជាប់ឈ្មោះថា **ភូមិចាំបក់**។


At that time, the Majesty gave the royal order to have the forest cut down at the southwest of Taing Krasaing village for the residence of his concubines. It was then called “Phum Chambak ” ever since.






នៅខាងលិចឈាងខាងត្បូងភូមិចាំបក់ មានបឹងធំមួយជាកន្លែងដែលព្រះរាជាតែងតែនាំព្រះអគ្គមហេសី និងព្រះរាជបុត្រ ព្រមទាំងព្រះស្នំទៅក្រសាលសប្បាយដោយចាប់ត្រីរើសក្តាមខ្យង ដកព្រលិត បេះត្រកួនជាក្រយាស្ងោយ។

At the southwest of Chambak village, there was a big lake where the King always brought his wife and son along with his servants to visit and catch fish crabs or snails and pull up water lily and pick up the morning glory for food.




ថ្ងៃមួយ ព្រះរាជបុត្រយាងទៅក្រសាលនៅទីនោះជាមួយពួកស្រីស្នំ ក៏មិនស្រួលក្នុងព្រះកាយ ទ្រង់ព្រះកន្សែងយំយ៉ាងខ្លាំង ពួកស្រីស្នំក៏ច្រៀងបំពេបីបមថ្នមថ្នាក់បបោសអង្អែលដោយស្ងៀមស្ងាត់ ទើបនៅទីនោះជាប់ឈ្មោះថា **បឹងបំពេ** និង **បឹងខ្យង**។

One day, the prince went to play there with the women servants. Suddenly, the prince burst into tears so the women servants sang and comforted him quietly and there it was called “Boeng Bampe and Boeng Kyang” or Comfort Lake and Snail Lake.



នៅខាងជើងបឹងបំពេ មានភ្នំមួយហៅភ្នំធំ ស្រះខ្មៅ ភ្នំពេនជុំ។ ភ្នំទាំងនេះ ស្ថិតនៅជាប់ៗគ្នាជាទីដែលព្រះរាជាតែងតែនាំព្រះអគ្គមហេសីឡើងទៅ ក្រសាលបេះផ្លែឈើមាន ផ្លែភ្នំភ្លែង ព្រីង ផ្លែព្លោ សិរមាន់ ជើងចាប និង ផ្លែឈើឯទៀតៗជាច្រើន ដោយព្រះអង្គសព្វព្រះរាជហឫទ័យក្រៃលែង។

The north of Comfort Lake, There was a mountain called Phnom Thom Sreh Khmao, Phnom Penchum. These mountains were situated closely together where the King often took his wife to pick the forest fruits such as Phnom Phnaeng blackberry, eagle marmelos, dasymaschalon iomentaceum, celosia fruit and other fruits which are their favorites.







មានថ្ងៃមួយ ព្រះរាជាបាននាំព្រះអគ្គមហេសីព្រមទាំងបុត្រទៅក្រសាលលើភ្នំ។ ពេលនោះព្រះរាជបុត្រក៏ស្រាប់តែប្រឈួនជាខ្លាំង ទ្រង់ចាត់នាម៉ឺនឱ្យកាប់ឆ្កាព្រៃមួយកន្លែងក្បែរជើងភ្នំធ្វើព្រះពន្លា ហើយបណ្តោះព្រះមហេសី និងព្រះរាជបុត្រព្រមទាំងមនុស្សទាំងអស់មកសម្រាកក្បែរជើងភ្នំ ហើយនៅទីនោះក៏ជាប់ឈ្មោះថា **ភូមិបណ្តោះ** ដល់ពេលយូរៗទៅក៏ប្រែជា **ភូមិក្រគោះ**។

One day, the King took his wife and his son to visit on the top of the mountain. Meanwhile, the son fell serious sick, therefore the king ordered the officials to cut down the forest at the foot of the mountain to build a lodge and they all temporarily stayed there and it was called “Bandos Village” and later was changed to “Krakoh village.”



បន្ទាប់មក ព្រះរាជានាំព្រះរាជបុត្រមកគង់នៅព្រះពន្លាក្បែរជើងភ្នំ ទ្រង់បានរកពេទ្យហ្លួមកព្យាបាលព្រះរោគរបស់ព្រះរាជបុត្រ ប៉ុន្តែទោះបីជាឱសថរបស់ពេទ្យហ្លួនោះខ្លាំងពូកែយ៉ាងណាក៏ដោយ ក៏ព្រះរោគរបស់ព្រះរាជបុត្រវិតតែប្រឈួនខ្លាំងឡើងៗរហូតអស់ព្រះជន្មនៅទីនោះ។


Then the King took his son to stay in the lodge near the foot of mountain and the King seeked for the doctors to cure his son. Though the medicine was effective, it unfortunately could not cure the prince. The prince's sickness got so serious that he passed away there.



ព្រះរាជា និងព្រះអគ្គមហេសី ទ្រង់ព្រះកន្សែងយំ
សោកយ៉ាងខ្លាំង ហើយធ្វើឈាបនកិច្ចជាឧឡារិក
នៅទីនោះ។ កន្លែងជើងភ្នំដែលព្រះរាជាធ្វើព្រះពន្លា
ព្យាបាលព្រះរាជបុត្រលុះអស់ព្រះជន្មជា
អាសន្នជាប់ឈ្មោះថា **ភ្នំអាសន្នមានទុក្ខ**
លុះតគ្គាមកក៏ជាប់ជា **ភ្នំសន្ធក** និង
ភូមិសន្ធក រហូតមកដល់សព្វថ្ងៃនេះ។




The King and the Queen cried and felt very upset. The Prince's corpse was cremated there. The foot of the mountain, where the King built the lodge to cure his son, was called "Ason Mountain". This mountain has been called "Phnom Santhok" ever since onward to nowadays.



ក្រោយពេលដែលព្រះរាជបុត្រសោយទីវង្គត់ទៅ ព្រះរាជា និង ព្រះមហេសី សម្រេចព្រះទ័យយាងចេញអំពីព្រះរាជវាំង ធ្វើដំណើរទៅ ឈប់សំចតនៅមាត់ស្ទឹងសែនដើម្បីរំសាយទុក្ខ។

After the death of their son, the King and the Queen decided to leave the Royal palace to stay at Stoeung Sen for relief.




គ្រានោះ មានសាមណេរមួយអង្គបាននិមន្តទៅជួបនឹងព្រះរាជា។ ហើយលោកបានឃើញទ្រង់ និងព្រះអគ្គមហេសីមានទុក្ខសោកដូច្នេះ ក៏ថ្វាយព្រះពរសួរ។

Meanwhile there was a monk who went past and noted that the King and the Queen were very sad so he asked what happened to them.




ព្រះរាជា ទ្រង់ថ្លែងសេចក្តីទុក្ខអំពីព្រះរាជបុត្រដែលរំលត់ខន្ធបាត់ទៅហើយ។ ទោះបីសាមណេរខំអធិប្បាយ រីពន្យល់ពីធម៌អាថ៌ល្អិតល្អន់យ៉ាងណាក៏ដោយ ក៏ស្តេចទាំងពីរព្រះអង្គនៅតែមិនបាត់នូវសេចក្តីវិយោគសោកស្តាយព្រះរាជបុត្រនោះឡើយ។



The King told the monk that he was upset because his son died. Though the monk tried to explain about the reason and Dharma, the King and Queen still suffered from the death of their son.

សាមណេរបានជ្រាបរឿងនេះពិតប្រាកដហើយ ទ្រង់ក៏ថ្វាយព្រះពរ "បើព្រះអង្គចង់ឃើញព្រះរូបព្រះរាជបុត្រនោះ សូមទ្រង់ឱ្យជាងយកម្សៅ ឬដីមកសូនធ្វើជាព្រះរូបរបស់ព្រះរាជបុត្រ ទុកគ្រាន់ទតរំសាយទុក្ខ ព្រះទ័យរបស់ព្រះអង្គ"។

After the monk knew what happened, he said:"If your majesty wants to see body of the son, please order the sculptors to take the wax or land to make the stature of the prince so that you can see your son and recover from the suffering".




ព្រះរាជាបានឮសាមណេរមានពុទ្ធដីការដូច្នេះ ក៏មានព្រះទ័យត្រេកអរជាខ្លាំង ហើយចាត់ឱ្យជាងធ្វើរូបសំណាកព្រះរូបព្រះរាជបុត្រនៅទីនោះ។




After the King listened to the monk, the King and the Queen felt very happy and ordered the sculptors to make the stature of the prince there.

លុះធ្វើរូបព្រះរាជបុត្រសព្វគ្រប់ហើយ ព្រះអង្គទាំងពីរទតមើលសព្វ ព្រះរាជហឫទ័យជាខ្លាំង ថែមទាំងបានធូរស្រាលទុក្ខសោកទាំងឡាយ ដែលបានឃើញរូបសំណាកព្រះរូបព្រះរាជបុត្រជាតំណាង ទើបទីកន្លែង នោះជាប់ឈ្មោះថា **ភូមិសំណាក**។



When the stature of the prince was already built, they both watched it happily and looked relief. That place was named "Phum Samnak" or "Stature Village".

ក្រោយមក ព្រះរាជាក៏នាំព្រះអគ្គមហេសីយាងទៅក្រសាលកន្លែងមួយនៅខាងជើងទីតំកល់រូបសំណាកព្រះរាជបុត្រ។ ទ្រង់បានទតឃើញឆ្អឹងក្បាលក្រពើមួយដែលស្លាប់យូរណាស់មកហើយ ទើបនៅទីនោះជាប់ឈ្មោះថា **ភូមិត្បូងក្រពើ**។ **ចប់**



Next the King took the Queen to visit the place at the north of stature of the prince. The King saw the bone of crocodile head that was dead for a long time. And there it was called “Phum Tboung Krapeu” or “Crocodile Bone Village” ever since. **The End**